**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ✓ មស.

# សេចក្តីជូនដំណឹង

យោងតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣ ក្រសួងមុខងារសាធារណៈ សូមជូនដំណឹងដល់អតីតបុគ្គលិកវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ដែលមានបំណងចូលបម្រើការងាររដ្ឋតាមក្រសួង-ស្ថាប័ន មេត្តាមកធ្វើការទំនាក់ទំនងជាមួយនាយកដ្ឋានជ្រើសរើសមន្ត្រីរាជការនិងបុគ្គលិកបម្រើការងាររដ្ឋ នៃក្រសួងមុខងារសាធារណៈ ដើម្បីបំពេញបែបបទតាមនីតិវិធីកំណត់។

អ្នកចូលមកដាក់ពាក្យ សូមភ្ជាប់មកជាមួយនូវបណ្ណសម្គាល់អតីតបុគ្គលិក VOD នៅរៀងរាល់ថ្ងៃធ្វើការ ពេលព្រឹកចាប់ពីម៉ោង ០៨:០០នាទី ដល់ម៉ោង ១១:៣០នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០នាទី ដល់ម៉ោង ១៧:០០នាទី តាមរយៈអាសយដ្ឋាន ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

ព័ត៌មានបន្ថែម សូមទំនាក់ទំនងលេខទូរស័ព្ទ: ០៨៩ ៩៧៨ ៦៧៨ និង ០១៧ ៦៥១ ៣២៣។

ថ្ងៃសុក្រ ១២រោច ខែមាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២៣

**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងមុខងារសាធារណៈ**
លេខ : ៨១៧ /២៣ មស.សសរ

ថ្ងៃ សុក្រ ១២ រោច ខែ មាឃ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ២០២៣

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតគណៈកម្មការរៀបចំការទទួលពាក្យរបស់អតីតបុគ្គលិកវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ដែលមានបំណងចូលបម្រើការងាររដ្ឋតាមក្រសួង-ស្ថាប័ន

## រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងមុខងារសាធារណៈ
- យោងអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** កាលពីថ្ងៃទី១៤ ខែកុម្ភៈ ឆ្នាំ២០២៣
- យោងតាមការចាំបាច់ និងសំណូមពរការងារ។

## សម្រេច

**ប្រការ ១៖** បង្កើតគណៈកម្មការរៀបចំការទទួលពាក្យរបស់អតីតបុគ្គលិកវិទ្យុសំឡេងប្រជាធិបតេយ្យ (VOD) ដែលមានបំណងចូលបម្រើការងាររដ្ឋតាមក្រសួង-ស្ថាប័ន ដែលមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| ១. ឯកឧត្តម **អែម ម៉ុនថុល** | រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | ប្រធាន |
| ២. ឯកឧត្តម **ប៉ែន បូណា** | រដ្ឋលេខាធិការ ក្រសួងព័ត៌មាន | អនុប្រធាន |
| ៣. ឯកឧត្តម **សយ រតនៈ** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក | សមាជិក |



ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

| | | |
|---|---|---|
| ៤. ឯកឧត្តម **ឈុន សុជាតិ** | ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកជាអគ្គនាយក | សមាជិក |
| ៥. ឯកឧត្តម **ហាស់ ម៉ិនថុន** | អនុរដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ | សមាជិក |
| ៦. ឯកឧត្តម **រោទ ឈុទ** | អគ្គនាយក ក្រសួងមុខងារសាធារណៈ | សមាជិក |
| ៧. ឯកឧត្តម **យឿន សម្បត្តិ** | អគ្គនាយក ក្រសួងមុខងារសាធារណៈ | សមាជិក |
| ៨. លោក **ចាន់ ទាសនា** | អគ្គនាយករង ក្រសួងមុខងារសាធារណៈ | សមាជិក |
| ៩. លោក **គង់ សុខត្ថិភាព** | អគ្គនាយករង ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១០. លោក **ទេព តារុន** | អគ្គនាយករង ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១១. លោក **ពេជ្រ និពន្ធ** | អគ្គនាយករង ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១២. លោក **អៀង គីមលាង** | ប្រធាននាយកដ្ឋាន ក្រសួងមុខងារសាធារណៈ | សមាជិក |
| ១៣. លោក **សោម សារទេត** | ប្រធាននាយកដ្ឋាន ក្រសួងមុខងារសាធារណៈ | សមាជិក។ |

**ប្រការ ២ ៖** គណៈកម្មការនេះ មានភារកិច្ចដូចខាងក្រោម៖

- ទទួលពាក្យអតីតបុគ្គលិកវិទ្យុសំឡេងប្រជាធិបតេយ្យ(VOD) ដែលមានបំណងចង់ចូលបម្រើការងាររដ្ឋ
- ពិនិត្យ និងផ្ទៀងផ្ទាត់ លើសំណុំឯកសាររបស់អតីតបុគ្គលិកវិទ្យុសំឡេងប្រជាធិបតេយ្យ(VOD) ដើម្បីរៀបចំបញ្ចូលក្របខ័ណ្ឌស្របតាមសមត្ថភាព ជំនាញវិជ្ជាជីវៈ និងឧបនិស្ស័យការងាររបស់បុគ្គលិកម្នាក់ៗ
- រៀបចំឯកសារពាក់ព័ន្ធ សម្រាប់ដាក់បញ្ចូលក្របខ័ណ្ឌឱ្យស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន
- សម្របសម្រួលជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីបញ្ចូលក្របខ័ណ្ឌអតីតបុគ្គលិកវិទ្យុសំឡេងប្រជាធិបតេយ្យ(VOD) ដែលមានបំណងចង់ចូលបម្រើការងាររដ្ឋ
- បូកសរុបរបាយការណ៍ជាប្រចាំជូនឯកឧត្តមរដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ ដើម្បីលើកសំណើគោរពជូនប្រមុខរាជរដ្ឋាភិបាលពិនិត្យ និងសម្រេចដ៏ខ្ពង់ខ្ពស់
- បំពេញភារកិច្ចផ្សេងៗទៀត តាមការប្រគល់ជូនរបស់រដ្ឋមន្ត្រីក្រសួងមុខងារសារធាណៈ។

**ប្រការ ៣ ៖** នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានគ្រប់គ្រងមុខងារសាធារណៈ អគ្គនាយនៃអគ្គនាយកដ្ឋានគោលនយោបាយមុខងារសាធារណៈ អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការទូទៅ អគ្គនាយកនៃអគ្គនាយកដ្ឋានផែនការ ស្ថិតិ និងគ្រប់គ្រងមន្ត្រីរាជការតាមប្រព័ន្ធព័ត៌មានវិទ្យា អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកសាលាភូមិន្ទរដ្ឋបាល ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ៕

រដ្ឋមន្ត្រី

ព្រុំ សុខា

**ចម្លងជូន៖**
-ទីស្ដីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
-ក្រសួងព័ត៌មាន
-ខុទ្ទកាល័យសម្ដេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
" ដើម្បីជូនជ្រាប "
-ដូចប្រការ១ និងប្រការ៣ (ដើម្បីអនុវត្ត)
-ឯកសារ កាលប្បវត្តិ